ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ

# ដំណឹងជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា

ដើម្បីផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការបញ្ជាក់លើការស្នើសុំទូទាត់ចំណាយសេវាសុខាភិបាលនៃមូលនិធិសមធម៌សុខាភិបាល និងសេវាវេជ្ជសាស្ត្រនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ, **ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ (ទ.ជ.ប.)** មានតម្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា មកបម្រើការជា**មន្ត្រីតាមដានត្រួតពិនិត្យមូលនិធិសមធម៌សុខាភិបាល** ចំនួន **៤ រូប (១រូប/ខេត្ត)** រួមមាន ខេត្តស្វាយរៀង, ឧត្តរមានជ័យ, កំពង់ចាម និងកោះកុង។ មន្ត្រីតាមដានត្រួតពិនិត្យមូលនិធិសមធម៌សុខាភិបាល ដែលត្រូវបានជ្រើសរើស ត្រូវមានភារកិច្ច និងការទទួលខុសត្រូវ ព្រមទាំង គុណវុឌ្ឍិ និងជំនាញបច្ចេកទេស ដូចខាងក្រោម៖

❖ **ភារកិច្ច និងការទទួលខុសត្រូវ**

- ពិនិត្យផ្ទៀងផ្ទាត់ឯកសារមូលនិធិសមធម៌សុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាល
- សម្ភាសន៍តាមខ្នងផ្ទះអ្នកជំងឺដែលបានមកប្រើប្រាស់សេវារបស់មូលដ្ឋានសុខាភិបាល
- បញ្ចូលលទ្ធផលតាមដានត្រួតពិនិត្យប្រចាំខែ ទៅក្នុងប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ (PMRS)
- ធ្វើរបាយការណ៍តាមដានត្រួតពិនិត្យមូលនិធិសមធម៌ប្រចាំខែ ផ្ញើជូនមន្ត្រីបច្ចេកទេសហិរញ្ញប្បទានមូលនិធិសមធម៌សុខាភិបាលដើម្បីពិនិត្យ និងកែសម្រួល
- ផ្តល់ជំនួយបច្ចេកទេសជូនមូលដ្ឋានសុខាភិបាល លើការអនុវត្តមូលនិធិសមធម៌សុខាភិបាល
- ពិនិត្យ វិភាគទិន្នន័យប្រើប្រាស់សេវានិងការទូទាត់របស់មូលដ្ឋានសុខាភិបាល ក្នុងតំបន់ទទួលខុសត្រូវ

❖ **គុណវុឌ្ឍិ និងជំនាញបច្ចេកទេស**

- ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ (បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប ឬ សញ្ញាបត្រវេជ្ជបណ្ឌិត)
- បទពិសោធការងារចាប់ពី ១ ឆ្នាំឡើងទៅ

**ការដាក់ពាក្យស្នើសុំជ្រើសរើស**

ការជ្រើសរើសនេះត្រូវបានបើកចំហដល់សាធារណៈជនទាំងអស់ ដែលមានគុណវុឌ្ឍិស្របតាមមុខតំណែង និងលក្ខខណ្ឌតម្រូវខាងលើ។ បេក្ខជន/បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមដាក់ពាក្យស្នើសុំដោយផ្ទាល់មក

ជាមួយនូវ Cover Letter និង CV តាមរយៈសារអេឡិចត្រូនិច (Email: **npca.job.hr@gmail.com**) យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង ៥និង៣០នាទីល្ងាច។**

សម្រាប់បេក្ខជន/បេក្ខនារី ដែលមានបំណងដាក់ពាក្យជាមន្ត្រីតាមដានត្រួតពិនិត្យមូលនិធិសមធម៌នៅតាមបណ្តាខេត្តទាំង៤ សូមធ្វើការបញ្ជាក់ឈ្មោះខេត្តដែលចង់ដាក់ពាក្យទៅបម្រើការងារឱ្យបានច្បាស់លាស់។

បេក្ខជន ជាស្ត្រី ឬជាជនមានពិការភាព ត្រូវបានផ្តល់អាទិភាព។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានធ្វើការទាក់ទង ដើម្បីសម្ភាស និងវាយតម្លៃ។